# ពេលវេលាស្ងប់ស្ងាត់ជាមួយព្រះជាម្ចាស់



ទារកត្រូវការអាហារសម្រាប់ចិញ្ចឹមរាងកាយឱ្យលូតលាស់យ៉ាងណា គ្រិស្តបរិស័ទដែលទើបនឹងជឿថ្មី ក៏ត្រូវការអាហារខាងវិញ្ញាណ ដើម្បីឲ្យលូតលាស់ខាងឯវិញ្ញាណដូច្នោះដែរ។ ព្រះយេស៊ូមានបន្ទូលថា៖

*"មនុស្សមិនមែនរស់ដោយសារតែនំបុ័ងប៉ុណ្ណោះទេ គឺរស់ដោយសារគ្រប់ទាំងព្រះបន្ទូលដែលចេញពីព្រះឱស្ឋរបស់ព្រះមកដែរ"»។ ម៉ាថាយ ៤:៤*

ដើម្បីទទួលបានអាហារបំប៉នខាងវិញ្ញាណនេះ គ្រិស្តបរិស័ទត្រូវមានពេលវេលាស្ងប់ស្ងាត់តែម្នាក់ឯង ជាមួយព្រះជាម្ចាស់។ ពេលវេលាស្ងប់ស្ងាត់ជាពេលវេលាមួយនៃទំនាក់ទំនងដ៏ជិតស្និទ្ធជាមួយព្រះអង្គ ដែលអាចធ្វើឱ្យយើងកាន់តែស្គាល់ទ្រង់ បំណងព្រះហឫទ័យរបស់ព្រះអង្គ



ព្រមទាំងការដឹកនាំ និងលក្ខណៈរបស់ព្រះអង្គសម្រាប់ជីវិតរបស់យើងថែមទៀត។ តាមរយៈការចំណាយពេលវេលាស្ងប់ស្ងាត់នោះ ទ្រង់ក៏បន្តចម្រើនកម្លាំងដល់យើងដែរ។

*«តែអស់អ្នកណាដែលសង្ឃឹមដល់ព្រះយេហូវ៉ាវិញនោះនឹងមានកម្លាំងចម្រើនជានិច្ច គេនឹងហើរឡើងទៅលើដោយស្លាបដូចជាឥន្ទ្រី គេនឹងរត់ទៅឥតដែលហត់ ហើយនឹងដើរឥតដែលល្វើយឡើយ»។ អេសាយ ៤០:៣១*

ព្រះគម្ពីរបានលើកទឹកចិត្តយើងឲ្យចំណាយពេលវេលាជាមួយនឹងព្រះជាម្ចាស់ ដែលនាំឲ្យយើងមានអំណរយ៉ាងលើសលប់។

*គឺអ្នកនោះត្រេកអរតែនឹងក្រឹត្យវិន័យរបស់ព្រះយេហូវ៉ាហើយសញ្ជឹងគិតអំពីក្រឹត្យវិន័យរបស់ព្រះអង្គទាំងយប់ទាំងថ្ងៃ។ ទំនុកតម្កើង ១:២*
ជាមួយគ្នានោះដែរ ក៏មាននៅក្នុងគម្ពីរ *ទំនុកតម្កើង* ១១៩:១៤៨ ។

ដើម្បីទទួលបាននូវអត្ថប្រយោជន៍ចេញពីការចំណាយពេលនោ យើងត្រូវរៀបចំផែនការសម្រាប់ពេលវេលាស្ងប់ស្ងាត់។ ចំណុចខាងក្រោមគឺជាចំណុចដែលត្រូវធ្វើការពិចារណា ៖

## ពេលវេលា

សូមសួរខ្លួនឯងថា តើពេលណាជាពេលវេលាដែលល្អបំផុតសម្រាប់ខ្ញុំ តើនៅពេលថ្ងៃ ឬក៏ពេលយប់ ដើម្បីចំណាយពេលជាមួយព្រះជាម្ចាស់ ដោយគ្មានការរំខាន? កិច្ចការដំបូងនៅពេលព្រឹក ជាវេលាដែលល្អសម្រាប់មនុស្សភាគច្រើន ប៉ុន្តែមានអ្នកខ្លះទៀតពេលល្ងាចគឺជាពេលវេលាដែលងាយស្រួលជាងសម្រាប់ពួកគាត់។ គ្រិស្តបរិស័ទម្នាក់ៗអាចមានពេលវេលាផ្សេងៗគ្នាសម្រាប់ពេលស្ងប់ស្ងាត់នេះ

ប៉ុន្តែសូមព្យាយាមចំណាយពេលឲ្យបានដប់ប្រាំនាទីក្នុងមួយថ្ងៃ។ ពេលវេលានោះអាចនឹងកើនឡើង នៅពេលដែលយើងនៅតែបន្តអនុវត្តជាប្រចាំ។

ពេលវេលាដ៏ងាយស្រួលបំផុតសម្រាប់ខ្ញុំជាមួយព្រះជាម្ចាស់ គឺចាប់ពី

---

## ទីកន្លែង

*ព្រឹកឡើង កាលនៅងងឹតនៅឡើយ ព្រះអង្គតើនឡើង ហើយយាងចេញទៅកាន់ទីស្ងាត់ រួចអធិស្ឋាននៅទីនោះ។ ម៉ាកុស ១:៣៥*

ប្រហែលវាមិនមែនជាពេលវេលាដែលសមស្របសម្រាប់លោកអ្នកក្នុងការចាកចេញពីផ្ទះដូចដែលព្រះយេស៊ូបានធ្វើនោះទេ ប៉ុន្តែសូមព្យាយាមធ្វើយ៉ាងណារកកន្លែងណាមួយ ដែលគ្មានការរំខាន ឬមាន តែតិចតួច ។

ទីកន្លែងដែលសមស្របបំផុតសម្រាប់ខ្ញុំ ចូលទៅកាន់ព្រះជាម្ចាស់គឺ

---

## ព្រះគម្ពីរ

សូមអានព្រះបន្ទូលមួយកថាខ័ណ្ឌ ឬមួយជំពូកជារៀងរាល់ថ្ងៃ។ មុនពេលដែលលោកអ្នកអាន សូមធ្វើការទូលសុំព្រះជាម្ចាស់ឲ្យមានបន្ទូលមកកាន់លោកអ្នកតាមរយៈព្រះបន្ទូលដែលលោកអ្នកអាននោះ ។

*សូមបំភ្លឺភ្នែកទូលបង្គំ ឲ្យបានឃើញការដ៏អស្ចារ្យនៅក្នុងក្រឹត្យវិន័យរបស់*

*ព្រះអង្គ។ ទំនុកតម្កើង ១១៩:១៨*

សូមណែនាំន្លែងដែលលោកអ្នកគួរចាប់ផ្ដើមអាន នោះគឺផ្ដើមពីដំណឹងល្អយ៉ូហានដែលនៅក្នុងព្រះគម្ពីរសញ្ញាថ្មី បន្ទាប់មកលោកអ្នកគួរអានកណ្ឌគម្ពីរកិច្ចការ ដែលជាកិច្ចការរបស់ពួកសាវ័ក។ល។



ចូរសញ្ជឹងគិតពីអ្វីដែលលោកអ្នកបានអាន។ ព្រះគម្ពីរពុំមែនគ្រាន់តែជាសៀវភៅប្រវត្តិសាស្ត្រជម្មតា ដែលសិក្សាពីអតីតកាលប៉ុណ្ណោះទេ ។ ព្រះគម្ពីរគឺជាព្រះបន្ទូលដ៏រស់របស់ព្រះជាម្ចាស់ ដែលមានព្រះបន្ទូលមកកាន់យើងនាពេលបច្ចុប្បន្ន។ ព្រះជាម្ចាស់កម្រមានព្រះបន្ទូលមកកាន់យើងតាម រយៈសំឡេងណាស់ ប៉ុន្តែជារឿយៗ ទ្រង់មានបន្ទូលមកយើងតាមមរយៈ ចំណាប់អារម្មណ៍ ឬជាគំនិតវិញ ។

| |
|---|
| កាលណាលោកអ្នកអានព្រះគម្ពីរ សូមសួរខ្លួនឯងនូវសំណួរទាំងនេះ៖<br>១. តើអត្ថបទគម្ពីរនេះនិយាយអំពីអ្វីខ្លះ?<br>២. តើមានអ្វីដែលខ្ញុំមិនយល់ដែរឬទេ?<br>៣. តើខ្ញុំអាចយកអត្ថបទគម្ពីរនេះមកអនុវត្តបានយ៉ាងដូចម្ដេចដែរ? |

ការអានព្រះបន្ទូលអាចធ្វើឱ្យលោកអ្នកយកមកអនុវត្តបានតាមរបៀបផ្សេងៗគ្នាដែរ ។ ឧទាហរណ៍ ប្រហែលជាមានការបង្គាប់មួយដែលលោកអ្នកត្រូវស្ដាប់បង្គាប់តាម ការព្រមានមួយ ដែលត្រូវយកចិត្តទុកដាក់ ព្រះបន្ទូលសន្យា ឬគំរូមួយដែលត្រូវយកតម្រាប់តាម ។

ត្រូវមានសៀវភៅមួយក្បាលសម្រាប់ធ្វើការកត់ត្រាជារៀងរាល់ថ្ងៃ ជាប្រយោជន៍ ដើម្បីឲ្យលោកអ្នកអាចឆ្លើយតបនឹងសំណួរទាំងនេះបាន។ វាជួយឱ្យយើងងាយស្រួលចងចាំនូវរាល់គំនិតប្រចាំថ្ងៃទាំងនោះ។ បើមានអ្វីមួយដែលលោកអ្នកមិនយល់ លោកអ្នកច្បាស់ជាត្រូវសួរអ្នកផ្សេងទៀត ឬរកមើលនៅក្នុងវចនានុក្រមអត្ថាធិប្បាយព្រះគម្ពីរ។

## ការអធិស្ឋាន

ការអធិស្ឋានជាការទូលទៅកាន់ព្រះជាម្ចាស់។ ជួនកាលការអធិស្ឋានមានភាពងាយស្រួល ហើយមានពេលខ្លះទៀតការអធិស្ឋានក៏មិនងាយស្រួលនោះដែរ ។ នៅពេលដែលកូនៗរបស់យើងនិយាយមកកាន់យើង យើងប្រាកដជាចាំស្ដាប់ពួកគេ។

ចុះទម្រាំតែព្រះបិតារបស់យើងដែលគង់នៅស្ថានសួគ៌ ពេញដោយសេចក្តីស្រឡាញ់ ទ្រង់ប្រាកដជាចង់ស្តាប់យើងច្រើនជាងអម្បាលមាននៅទៀត។ ជួនកាលការអធិស្ឋានជាការនៅស្ងៀម ដោយគ្រាន់តែអនុញ្ញាតឱ្យព្រះជាម្ចាស់មានព្រះបន្ទូលដោយស្ងៀមស្ងាត់មកកាន់យើងប៉ុណ្ណោះ។

ពេលអ្នកអធិស្ឋានៈ
១. ចូរសារភាពរាល់កំហុសទាំងអស់។ សូមអាន ១យ៉ូហាន ១:៩ ។
២. ចូរអរព្រះគុណ និងសរសើរតម្កើងព្រះជាម្ចាស់ចំពោះកិច្ចការដែលទ្រង់បានធ្វើ និងដោយព្រោះព្រះអង្គជានរណា។ ភីលីព ៤:៦ ក៏បានណែនាំយើងឲ្យធ្វើតាមរបៀបនោះដែរ
៣.ចូរទូលសុំព្រះអង្គពីតម្រូវការរបស់លោកអ្នកនិងអ្នកដទៃ។ លូកា១១:១០-១៣ ដោយមានការធានាយ៉ាងច្បាស់ថាព្រះជាម្ចាស់សព្វព្រះហឫទ័យ នឹងឆ្លើយតបរាល់ការអធិស្ឋាន ។

ជាការចាំបាច់លោកអ្នកត្រូវរក្សាកំណត់ត្រានៅក្នុងសៀវភៅសំណូមពរអធិស្ឋាន និងការឆ្លើយតបការអធិស្ឋាន។ ឧទាហរណ៍...

| **សំណូមពរអធិស្ឋាន** | **ថ្ងៃទូលសុំ** | **ថ្ងៃទទួលបានចម្លើយ** |
| --- | --- | --- |
| សូមជួយដល់ទូលបង្គំឱ្យចេះចែកចាយជំនឿជាមួយនឹង សុភា។ | | |
| តើទូលបង្គំបានធ្វើការសម្រេចចិត្តត្រឹមត្រូវដែរឬទេនៅកន្លែងធ្វើការ? | | |
| សូមជួយទូលបង្គំឱ្យស្រឡាញ់អ្នកជិតខាងរបស់ទូលបង្គំផង ។ | | |



ត្រូវមានគំនិតច្នៃប្រឌិតរកវិធីសាស្រ្តនៅក្នុងការចំណាយពេលវេលាស្ងៀមស្ងាត់នេះ ជាពិសេសសម្រាប់ខ្លួនលោកអ្នកផ្ទាល់។ អាចជាការគូររូបភាព
ការសរសេរជាបទចម្រៀងផ្ទាល់ខ្លួនដើម្បីថ្វាយបង្គំព្រះជាម្ចាស់
ការកត់ត្រានូវព្រះពររបស់លោកអ្នក ឬទាញយកខព្រះគម្ពីរ និងបទចម្រៀងថ្វាយបង្គំនៅលើ Ipod របស់លោកអ្នក។ សូមដាក់វិន័យលើខ្លួនឯង ឱ្យចេះចំណាយពេលវេលាស្ងប់ស្ងាត់ជារៀងរាល់ថ្ងៃ និងចែកចាយនូវអ្វីដែលអ្នកបានរៀនជាមួយអ្នកដទៃ នេះក៏ជាការលើកទឹកចិត្តដល់ពួកគេផងដែរ។